ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី

លេខ: ២៣៨

ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០១

សាលដីកា

លេខ: ២០៦

ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ២០០២

នាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជម្រះ ជាសាធារណៈនៅថ្ងៃទី ២៧ ខែសីហា ឆ្នាំ ២០០២ ដោយមានសមាសភាពដូចតទៅ:-

១- ឯកឧត្តម ឌិត មុន្ទី ជាប្រធាន

២- លោក វៀល ខួន ជាចៅក្រម

៣- លោក ស៊ិន ឌឹម ជាចៅក្រម

៤- លោក ជីវ កេង ជាចៅក្រម

៥- លោក ប្រាក់ គឹមសាន ជាចៅក្រម

៦- លោក ឈឹម ស៊ីផល ជាចៅក្រម

៧- លោក យស់ សុខឿន ជាចៅក្រម

៨- លោក សោម សិរីវុឌ្ឍ ជាចៅក្រម

៩- លោក ខ័ន សាវឿន ជាចៅក្រមរបាយការណ៍

ក្រឡាបញ្ជី

លោក ម៉ៅ សុវណ្ណ

តំណាងមហាអយ្យការ

លោក យួន ចាន់ថា ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជម្រះលើបណ្ដឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ ៧៥ "ឃ" ចុះថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ ២០០០ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ០៦ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ ។

រវាងដើមចោទឈ្មោះ ពេជ្រ ទីម "ចុងបណ្ដឹងសាទុក្ខ" ភេទប្រុស អាយុ ៤៨ឆ្នាំ ជាតិខ្មែរ មុខរបរ អភិបាលស្រុករង មានទីលំនៅភូមិមណ្ឌល ៣ ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប ។ ឪពុកឈ្មោះ ពេជ្រ អ៊ិត "ស" ម្ដាយឈ្មោះម៉ក់ រិច "ស" ប្រពន្ធឈ្មោះពាន ទេរឹម ។ ផ្ទេរសិទ្ធិអោយឈ្មោះ អោម ទេរឿន ។

និងចុងចម្លើយឈ្មោះ ខាន់ សុខុន " ម្ចាស់បណ្តឹងសាទុក្ខ " ភេទប្រុស អាយុ ៣៣ ឆ្នាំ ជាតិខ្មែរ មុខរបរ គ្រូបង្រៀន មានទីលំនៅសព្វថ្ងៃភូមិចំបក់ចែត ឃុំពួក ស្រុកពួក ខេត្តសៀមរាប ។ ឪពុកឈ្មោះ អ៊ុន ខឿន " ស " ម្តាយឈ្មោះ ស្លុង យ៉ាន " រស់ " ប្រពន្ធឈ្មោះ ឈិន គឹមឡា មានកូន ០៤ នាក់ ។

មានមេធាវី លោក ង៉ែត ឃី ។

កម្មវត្ថុបណ្តឹង : ប្តឹងអោយរុះរើដេប៉ូឈើចេញពីដី

តាម.បណ្តឹងសាទុក្ខលើកទី ២ លេខ ៤៣៧ ចុះថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០០០ របស់ឈ្មោះ ខាន់ សុខុន ប្តឹងមិនសុខចិត្តនឹងសាលដីការបស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ២៣៩ ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០១ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ២៧.១២.៩៦ របស់ឈ្មោះ ពេជ្រ រ៉ែម តំណាងអោយអភិបាល-ស្រុកពួកប្តឹងសុំអោយឈ្មោះ ខាន់ សុខុន រុះរើដេប៉ូឈើចេញលើដីរបស់ខ្លួន ដោយអាងហេតុថាដីនេះជាដីរបស់ស្រុកពួកដែលបានគ្រប់គ្រងតាំងពីឆ្នាំ ១៩៧៩ ។ នៅឆ្នាំ ១៩៨៧ ស្រុកពួកសាងសង់ដេប៉ូលក់ឈើនៅលើដីនោះប្រកបរបរហ៊ុនគ្នាជាមួយឈ្មោះ ឈិន លា ។ នៅឆ្នាំ១៩៩០ ស្រុកបានកាត់ហ៊ុនពីឈ្មោះ ឈិន លា ហើយអនុញ្ញាតអោយឈ្មោះ ឈិន លា ប្រកបរបរលក់ស្តូរនៅលើដីនោះជា-បណ្តោះអាសន្ន ។ ក្រោយមកឈ្មោះ ឈិន លា បានផ្ទេរដី និង រោងដេប៉ូឈើអោយទៅចុងចម្លើយគ្រប់គ្រង ហើយចុងចម្លើយបានសង់តូបថ្មីមួយបន្ថែមទៀត ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ៩៩ ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ ១៩៩៧ របស់តុលាការខេត្តសៀមរាប ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :-

១- ទទួលពាក្យបណ្តឹងរបស់ដើមចោទទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- បដិសេធបណ្តឹងសុំសិទ្ធិគ្រប់គ្រងដីរបស់ចុងចម្លើយចោល ដោយខុសនឹងគតិច្បាប់ ។

៣- ទទួលស្គាល់ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ សេ៦-៦៥០ ចុះថ្ងៃទី ១៩-១០-៩៤ ទុកជាត្រឹមត្រូវតាមច្បាប់ ។

៤- សំរេចអោយចុងចម្លើយ និង ក្រុមគ្រួសារ រុះរើសំណង់ទាំងអស់ចេញពីលើដីកំពុងមានទំនាស់ ចំណែកគ្រឿងប្រក់ដេប៉ូលក់ឈើនិង ឈើសំណង់ដេប៉ូពាក់កណ្តាលត្រូវប្រគល់អោយទៅអភិបាល-ស្រុកពួក ។

៥- សំរេចអោយចុងចម្លើយបង់ប្រាក់ប្រដាប់ក្តី ពន្ធចុះបញ្ជីក្តី និង ពន្ធហ្លឹង ១៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រៀល រង្វាន់អ្នកប្រគល់ដីកាកោះ ៥.០០០រៀល បូករួម ៧.០០០រៀល ។ប្រាក់នេះបានកាត់យកពីប្រាក់ ៧.០០០រៀល ដែលដើមចោទបានបង់ទុករួចហើយ ។

កាលបើប្តឹងឧទ្ធរណ៍ត្រូវបង្គាប់អោយចុងចម្លើយសងប្រាក់ ៧.០០០រៀលនេះទៅដើមចោទវិញ និងអោយបង់ពន្ធសមាមាត្រ ៤៧.០០០រៀលបន្ថែមទៀត ដែលត្រូវដាក់ថវិការដ្ឋ ៣៧.៦០០រៀល និងរង្វាន់ក្រឡាបញ្ជីក្នុងកម្ពុជា ៩.៤០០រៀល ។ ពន្ធសមាមាត្រនេះត្រូវអោយដើមចោទបង់មុនដែរ ទើបបង្គាប់អោយចុងចម្លើយសងទៅដើមចោទវិញជាក្រោយ ។

៦_សាលក្រមនេះ ប្រកាសជាសាធារណៈចំពោះមុខគូភាគី បើកផ្លូវឧទ្ធរណ៍កំណត់ពីរខែ គិតពីថ្ងៃនេះតទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ២០ ចុះថ្ងៃទី ០៦ ខែតុលា ឆ្នាំ ១៩៩៧ របស់លោក_ខាន់ សុខុន ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ៩៩ ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ១៩៩៧ របស់តុលាការខេត្តសៀមរាបទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៣៣៣ ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ:_

១_ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ០៦.១០.១៩៩៧ របស់ឈ្មោះ ខាន់ សុខុន ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២_បដិសេធសាលក្រមរដ្ឋប្បវេណីលេខ ៩៩ ចុះថ្ងៃទី ២២.៨.១៩៩៧ របស់តុលាការខេត្តសៀមរាប ចោលជាអាសារបង់ ។

៣_បដិសេធប័ណ្ណសំគាល់សិទ្ធិកាន់កាប់ និង ប្រើប្រាស់ដីធ្លីលេខ សេ៦_៦៥០ ចុះថ្ងៃទី ១៩_១០_១៩៩៤ ចោលជាអាសារបង់ ។

៤_ប្រគល់ដីទំនាស់ទំហំ ៤២,៣០ម គុណ ២៤,៥០ម តាមគំនូសប្លង់បង្ហាញទីតាំងដីទំនាស់ "ចំណុច ១" ស្ថិតនៅភូមិចំបក់ហែ ឃុំពួក ស្រុកពួក ខេត្តសៀមរាប ទៅអោយឈ្មោះ_ខាន់ សុខុន កាន់កាប់គ្រប់គ្រងជាកម្មសិទ្ធិនៅពេលដែលសាលដីកានេះចូលជាស្ថាពរ ។

៥_សំរេចកាត់យកប្រាក់ប្រដាប់ក្តីចំនួន ១៣.០០០រៀល ដែលដើមបណ្តឹងឧទ្ធរណ៍បានបង់រួចហើយគឺពន្ធចុះបញ្ជីក្តី និង ពន្ធថ្លឹង ២៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាត់ចិតប្រាក់ ៤៥០រៀល ចំណាយលើការប្រគល់ដីកាកោះ ៥.០០០រៀល និង លើអាផ្ទាធរតុលាការ ៥.០០០រៀល ។

_កាលបើសាលដីកានេះចូលជាស្ថាពរហើយ បង្គាប់អោយចុងបណ្តឹងឧទ្ធរណ៍សងប្រាក់ ១៣.០០០រៀល នេះ ទៅដើមបណ្តឹងឧទ្ធរណ៍វិញ ។

៦_សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្តី ។

_សំរេចបើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៣០៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៨ របស់លោក ពេជ្រ ទឹម ប្តឹងមិនសុខចិត្តនឹងសេចក្តីសំរេចរបស់សាលាឧទ្ធរណ៍ទាំងមូល ។

--- ----

បានឃើញសាលដីការដ្ឋប្បវេណីលេខ ២៧០ ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ១៩៩៩ របស់ តុលាការកំពូល ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅៈ-

១- ទទួលបណ្តឹងសាទុក្ខលេខ ៣០៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ១៩៩៨ របស់លោក- ពេជ្រ ម៉ែ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២- ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ៣៣៣ ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣- បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ២៦៩ ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៨ របស់ តុលាការកំពូល ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤- រឹបអូសប្រាក់ប្រដាប់ក្តី ដែលលោក ពេជ្រ ម៉ែ បានបង់ទុកនៅតុលាការកំពូល ចំនួន ១៩.០០០រៀល គឺៈ-

- ពន្ធចុះបញ្ជីក្តី និង ពន្ធហ្វឹងចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់។

- ចំណាយក្នុងការប្រគល់ដីកាកោះចំនួន ១៥.០០០រៀល សរុប ១៩.០០០រៀល ហើយត្រូវអោយចុងចម្លើយសងប្រាក់ចំនួន ១៩.០០០រៀលនេះទៅដើមចោទវិញ ។

៥- សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ១៩៩៩ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៧៩ "ឃ" ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍លើកទី ២ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅៈ-

១- ទទួលជំនុំជំរះជាសមត្ថកិច្ចតាមមាត្រា ១១ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាព សាលាជំរះក្តី ។

២- តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ៩៩ ចុះថ្ងៃទី ២២.៨.៩៧ របស់តុលាការ- ខេត្តសៀមរាប ទុកជាបានការពេញទាំងមូល ។

៣- សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលើកទី ២ លេខ ៤៣៧ ចុះថ្ងៃទី ០២ ខែវិច្ឆិកា ឆ្នាំ ២០០០ របស់លោក ខាន់ សុខុន ប្តឹងមិនសុខចិត្តនឹងសាលដីការបស់សាលាឧទ្ធរណ៍ទាំងមូល ធ្វើឡើងក្នុងកំណត់ច្បាប់។

បានឃើញសារណាចុះថ្ងៃទី ២៩ ខែ តុលា ឆ្នាំ២០០១ របស់ឈ្មោះ ខាន់ សុខុន ។

បានឃើញសារណាតបចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ របស់ឈ្មោះ កោម ទៀន ។

បានឃើញសាលដីការបៀបលេខ ៤២ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០២ របស់ តុលាការកំពូល ដែលបានសំរេចសេចក្តីដែលមានខ្លឹមសារដូចតទៅៈ-

១- ចាត់របៀបអោយចៅក្រមតុលាការកំពូល ធ្វើការស៊ើបអង្កេតបន្ថែម ដោយកោះ ហៅគូភាគី និង សាក្សីមកឆ្លើយបំភ្លឺបន្ថែម ។

២_ សាលដីកានេះ ប្រកាសតាមសវនាការជាសាធារណៈ នៅថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០២ ។

បានស្តាប់របាយការណ៍បញ្ចប់របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា ៖

_ បណ្តឹងសាទុក្ខលើកទី ២ របស់ចុងចម្លើយស្ថិតក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិនិត្យពិចារណា ។

_ សាលដីការដ្ឋប្បវេណីលេខ ៧៥ "យ" ចុះថ្ងៃទី ២៦.៩.០០ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ ។

សូមក្រុមប្រឹក្សាជំនុំជំរះ សំរេចតាមច្បាប់ ។

បានស្តាប់ចំលើយរបស់ឈ្មោះ ខាន់ សុខុន នាពេលសវនាការបានឆ្លើយបញ្ជាក់ថា ៖ខ្លួនគ្មានអ្វីបន្ថែមទេ ព្រោះខ្លួនបានដាក់ឯកសារក្នុងសំណុំរឿងអស់ហើយ ។

បានស្តាប់ចំលើយរបស់ឈ្មោះ អោម វឿន នាពេលសវនាការថា ៖ ក្នុងករណីវិវាទនេះ ខ្លួនបានជូនសំអាងដល់តុលាការអស់ហើយ ខ្លួនគ្មានអ្វីបន្ថែមទៀតទេ ។

លោក កែត ឃី មេធាវីការពារអោយចុងចម្លើយធ្វើសេចក្តីសន្និដ្ឋានថា ៖នៅឆ្នាំ១៩៧៩ ប្រធានភូមិ ចាក វ៉ាន់ ប្រគល់ដីស្រែមួយប្លង់អោយ ឈិន លា ។ ឆ្នាំ ១៩៨១ លោក ឈិន លា បានធ្វើជប៉ូលក់ឈើលើដីនោះ ។ ក្រោយមកលេខាបក្សស្រុកពួកបានសុំប្តូរដីនោះអោយទៅលោក _ ថូ សឿន ហើយបានប្រគល់ដីអោយលោក ឈិន លា ជាថ្នូរទំហំ ៣០ម គុណ ៧០ម លោក ឈិន លា បានធ្វើជប៉ូឈើលក់នៅកន្លែងថ្មីនេះ ។ នៅឆ្នាំ ១៩៩២ ក្រោយពីលោក អ៊ិន វង្ស ឡើងជាអភិបាលស្រុក ក៏ចាប់ផ្តើមចង់បានដីនេះយកទៅលក់ ។ រួមសេចក្តីមកកូនក្តីខ្លួនបានកាន់កាប់ស្របច្បាប់ ដូច្នេះដីទំនាស់នេះត្រូវតែបានមកកូនក្តីខ្លួនជាកម្មសិទ្ធិ ។

- ក្រោយពីបានស្តាប់របាយការណ៍បន្ថែមរបស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់គូភាគី និង សេចក្តីសន្និដ្ឋានរបស់មេធាវីចុងចម្លើយ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

### តុលាការកំពូល

_ យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៥៣៧ ចុះថ្ងៃទី ០២ ខែ ១១ ឆ្នាំ ២០០០ របស់លោក ខាន់ សុខុន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៥ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី និង មាត្រា ២២៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

- យល់ឃើញថា ការដែលចុងចម្លើយ បានលើកឡើងក្នុងសារណា ក៏ដូចការដែលមេធាវីចុងចម្លើយលើកនាពេលសវនាការនេះដែរ ដែលបានអះអាងថាដីទំនាស់នេះ លោក ជា សុផាត បានប្រគល់អោយឪពុកក្មេកលោកតាមលិខិតចុះថ្ងៃទី ០៥.០៨.៨៥ ហើយឪពុកក្មេកលោកបានធ្វើផ្ទះនៅ និងលក់ឈើបន្តទៀតតែម្នាក់ឯង ពុំមានការចូលហ៊ុនជាមួយស្រុកទេនោះ ជាការភ័ន្តច្រឡំពីព្រោះថា :.

- ដីនេះជាទ្រព្យសម្បត្តិរបស់ស្រុក ហើយការប្រគល់ទ្រព្យសម្បត្តិណាមួយរបស់ស្រុកអោយទៅឯកជនណាមួយត្រូវធ្វើដោយសេចក្តីសំរេចឆ្លងសម័យប្រជុំរបស់អង្គភាព ។

-មានភស្តុតាងគ្រប់គ្រាន់ថា ក្នុងការធ្វើអាជីវកម្មដេប៉ូឈើ ភាគហ៊ុនមួយចំនួនក៏ជារបស់ស្រុករួមទាំងសំភារៈសាងសង់ និង ក្រោមការគ្រប់គ្រងរបស់មន្ត្រីរុក្ខាប្រមាញ់ស្រុកផង ។

- យល់ឃើញថា :ការិយាល័យជំនាញភូមិបាលស្រុកនិង មន្ទីរសុរិយោដីខេត្តតាមលេខ-១៣០សដ.ខ.ស.វ ចុះថ្ងៃទី ២៧.៧.៩៧ និងលិខិតលេខ ០៥ភស-ស្រ.៣ ចុះថ្ងៃទី២៨.០៥.៩៧ ដែលបានបញ្ជាក់ថាចាប់ពីឆ្នាំ ១៩៧៩ ដីទំនាស់ស្ថិតនៅក្នុងបរិវេណប្រពន្ធ័ការពារទីរួមស្រុកគ្រប់គ្រងដោយកងទ័ពវៀតណាម ក្រោយវៀតណាមដក បានប្រគល់អោយស្រុកគ្រប់គ្រងបន្ត នៅឆ្នាំ ១៩៨៨ ស្រុកសំរេចអោយសង់អាគារប្រមូលផលរុក្ខារបស់ស្រុក ស្ថិតក្រោមការគ្រប់គ្រងរបស់កសិកម្មស្រុក ។

- យល់ឃើញថា : ដីទំនាស់នេះការិយាល័យភូមិបាលស្រុកបានធ្វើការអង្កេតវាស់វែងចុះថ្ងៃទី ៣.០៧.៩៣ ហើយត្រូវបានស្ថាប័នទំនាក់ទំនងដីធ្លីបានផ្តល់ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីជូនស្រុកពួកលេខ សេ៦-៦៥០ ចុះថ្ងៃទី ១៩.១០.១៩៩៥ ដូច្នេះប័ណ្ណសំគាល់សិទ្ធិនេះមានលក្ខណៈត្រឹមត្រូវហើយ ។

- យល់ឃើញថា : តាមលិខិតលេខ ២៦៥ស្រ.៣ ចុះថ្ងៃទី ១៨.១០.៩៥ របស់សាលាស្រុកពួកបញ្ជាក់ពីបញ្ជីសារពើភ័ណ្ឌដីធ្លីផ្ទះសំបែងអាគារបានកំណត់ច្បាស់ថាមានដីទំនាស់ស្ថិតនៅក្នុងបញ្ជីនេះដែលមានលោក អ៊ិន វង់ អតីតអភិបាលស្រុកដឹងឮ និង តាមលិខិតឆ្លើយតបរបស់អភិបាលខេត្ត-សៀមរាបលេខ ០៣៣ ស.ប.ក ចុះថ្ងៃទី ២៦.០៦.២០០២ បានបញ្ជាក់ និង ទទួលស្គាល់ដីទំនាស់ជាដីស្ថិតនៅក្នុងសម្បត្តិរដ្ឋផងដែរ ។

- យល់ឃើញថាការដែលចុងចម្លើយអះអាងថាខ្លួនបានបើកដេប៉ូឈើដោយផ្ទាល់មុខពីឆ្នាំ ១៩៨៥ ហើយបានដាក់ពាក្យសុំកាន់កាប់ប្រើប្រាស់ដីតាំងពីខែ ៦ ឆ្នាំ ១៩៩២ មក ហើយពុំទាន់បានទទួលកម្មសិទ្ធិនោះ ជាការបញ្ជាក់អោយឃើញថាដីទំនាស់ស្ថិតក្រោមការហួងហែងរបស់អាជ្ញាធរស្រុកហើយ ។

- យល់ឃើញថាការដែលមេធាវីចុងចម្លើយលើកឡើងថាដីទំនាស់ពុំមានក្នុងបញ្ជីសារពើ-ភ័ណ្ឌដោយសំអាងទៅលើកំណត់ហេតុចុះថ្ងៃទី ១៦.១២.៩៩ របស់ក្រុមអធិការកិច្ចរបស់ក្រសួងមហាផ្ទៃ និងលិខិតលេខ១៥០ ស.ជ.ណ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០០ នោះ ជាការពុំត្រឹមត្រូវទេពីព្រោះថា :តាមបញ្ជីសារពើភ័ណ្ឌលេខ ២៦៥ស្រ.៣ ចុះថ្ងៃទី ១៧.១០.៩៥ ដីនេះមានក្នុងបញ្ជីត្រង់លេខរៀង

ទី៣ ដូច្នេះប័ណ្ណលេខ ល៦-៦៥០ ចុះថ្ងៃទី ១៩.១០.៩៤ មានលក្ខណៈត្រឹមត្រូវហើយ ពីព្រោះ ប័ណ្ណនេះធ្វើចេញពីបញ្ជីសារពើភ័ណ្ឌ ។

- យល់ឃើញថា៖ សាលដីការដ្ឋប្បវេណីលេខ ៧៩ "ឃ" ចុះថ្ងៃទី ២៦.០៩.២០០០ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវទាំងទំរង់ទាំងគតិច្បាប់ហើយ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខគូក្តី

១- ទទួលបណ្តឹងសាទុក្ខលេខ ៤៣៧ ចុះថ្ងៃទី០២ ខែ ១១ ឆ្នាំ២០០០ របស់លោក- ខាន់ សុខុន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២- តំកល់សាលដីការដ្ឋប្បវេណីលេខ ៧៩ "ឃ" ចុះថ្ងៃទី ២៦ខែ ០៩ ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣- រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០រៀល ដែលលោក ខាន់ សុខុន បានបង់គឺ៖-

- ពន្ធចុះបញ្ជីក្តី និង ពន្ធរឹងចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន- ៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។
- ចំណាយលើការប្រគល់ដីកាកោះចំនួន ១៥.០០០រៀល សរុប ១៩.០០០រៀល

បង្គាប់អោយលោក ខាន់ សុខុន បង់ពន្ធសមាមាត្រតាមការកំណត់របស់តុលាការ ខេត្តសៀមរាប ។

៤- សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៧ ខែ០៨ ឆ្នាំ២០០២